គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC-CBC 22032018K

## សេចក្ដីថ្លែងការណ៍

# អំពី រដ្ឋធម្មនុញ្ញ, កោះត្រល់

នាថ្ងៃ១៧ មីនា ២០១៨ នៅមុខពលរដ្ឋខ្មែរ នៅអូស្ត្រាលី នាយករដ្ឋមន្ត្រី ហ៊ុន សែន បាន អះអាងថា រដ្ឋធម្មនុញ្ញរបស់កម្ពុជា (ឆ្នាំ១៩៩៣) មានចំណុចខ្សោយពីរ ជាហេតុនាំឲ្យពិបាក ក្នុងការតវ៉ា លើបញ្ហាទឹកដី ជាមួយប្រទេសជិតខាង ហើយគាត់ត្រូវប្រឹងប្រែងរក្សាទឹកដី បន្សល់ដោយ សម្ដេច នរោត្តម សីហនុ និងត្រូវប្រឹងបោះបង្គោលព្រំដែន ឲ្យបានរឹងមាំ។

គាត់បានអះអាងទៀតថា កោះត្រល់ (យួនហៅភូកុក) គឺអគ្គទេសាភិបាលបារាំង ឈ្មោះ (ហ្សុល) ប្រេវីយេ៉ (Jules Brévié) គូសកំណត់ ទៅឲ្យវៀតណាម តាំងពីឆ្នាំ១៩៣១មកម្ល៉េះ។ លុះនៅឆ្នាំ១៩៤៩ សភាបារាំង ក៏មានការប្រជុំរឿងកូសាំងស៊ីន រួមទាំងកោះត្រល់ដែរ តែខ្មែរមិនបានតវ៉ានោះទេ ថែមទាំងបោះឆ្នោតអនុប្បវាទថែមទៀតផង។

លោកហ៊ុន សែន បាននិយាយថា ចំណុចខ្សោយទី១ នៃរដ្ឋធម្មនុញ្ញ គឺការកំណត់ ចន្លោះឆ្នាំ១៩៣៣ និង១៩៥៣ នៃការធ្វើផែនទីកម្ពុជា ហើយទី២ គឺផែនទី ខ្នាត១លើ២០០ពាន់ ជាមួយថៃ អត់បានដាក់ ក្នុងរដ្ឋធម្មនុញ្ញនោះ ទេ។

យើងត្រូវដឹងថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នោះ ត្រូវបានតាក់តែង ជាបឋម ដោយសម្ដេច នរោត្តម សីហនុ និងលោកហ៊ុន សែន នេះឯង នៅក្នុងបំណងនយោបាយធំបំផុត គឺ ការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃកម្ពុជា **ដែលយួនហាណូយ ទើបតែបានឈ្លានពាន និងបានកាត់យកទឹកដី តាមអំពើចិត្ត។** ការកំណត់ច្បាស់ នូវចន្លោះឆ្នាំ១៩៣៣ និង១៩៥៣ គឺជាបំរាមមួយ មិនឲ្យមានការភ័ន្តច្រឡំ និងការបន្លឹមបន្លំ ក្នុងការប្រើប្រាស់ផែនទី នោះ។

យើងដឹងទៀតថា ផែនទីកម្ពុជា បានធ្វើឡើង ចន្លោះឆ្នាំ១៩៣៣-១៩៥៣នោះ ដោយយោងតាមសន្ធិសញ្ញានិងកិច្ចព្រមព្រៀងគ្នា ជាមុន ក្នុងអតីតកាល រវាងកម្ពុជានិងបារាំង (នៃដែនកូសាំងស៊ីន) មានជាអាទិ អនុសញ្ញាចុះថ្ងៃទី១៥ កក្កដា ១៨៧៣ ដែលមានការកំណត់បង្គោលព្រំដែន ចំនួន១២៤រួចហើយ។ ហេតុនេះ គេមិនបានប្រើ តែកិច្ចព្រមព្រៀងគ្នា ក្នុងចន្លោះឆ្នាំ១៩៣៣ និង១៩៥៣ នោះទេ។ រីឯរឿងព្រំដែន កម្ពុជា-ថៃ ទោះបីគេប្រើផែនទី ខ្នាត១លើ២០០ពាន់(ប្រព័ន្ធបោន)ក្ដី និងមិនបានបញ្ជាក់ ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាក្ដី ក៏គ្មាននរណាភ្លេចទេ ហើយគេបានយកផែនទីហ្នឹង មកប្រើប្រាស់ទៀត កាលលោក ហ៊ុន សែន ប្ដឹងទៅតុលាការអន្តរជាតិ នៃក្រុងឡាអេ អំពីការឈ្លានពាន របស់ថៃ នៅព្រះវិហារ នាឆ្នាំ២០០៨នោះ។

ក្នុងបញ្ហាកោះត្រល់វិញ សារាចរ(Circulaire)រដ្ឋបាល នៃថ្ងៃទី៣១ មករា ១៩៣៩ (មិនមែន ១៩៣១ទេ) នៃបារាំង ហ្សុល ប្រេវីយេ៉ មិនបានសរសេរថា គាត់កាត់កោះត្រល់ របស់កម្ពុជា ទៅឲ្យដែនកូសាំងស៊ីន (យៀកណាមសព្វថ្ងៃ) ទេ ។ មុ៉ាងទៀត "សារាចរ"រដ្ឋបាលបារាំង មិនមានតម្លៃច្បាប់ ស្មើនិង"សន្ធិសញ្ញា"ទេ ប៉ុន្តែវាមានតម្លៃទាបបំផុត នៅក្នុងឋានានុក្រមនៃច្បាប់បារាំង

ហើយវាគ្មានចង រដ្ឋបរទេសណាឡើយ។ ជាបន្ទាប់ ដោយគាត់ដឹងថា គាត់រំលោភលើរដ្ឋកម្ពុជា ទើបលោក ប្រេវីយេ៉ បានខំបញ្ជាក់ <u>ជាបឋម</u> ក្នុងសារាចរនោះ ថា "*យោងតាមការសមហេតុផល* ("logiquement") *និងតាមស្ថានភាពភូមិសាស្រ្ត ការចាំបាច់ តម្រូវឲ្យគេដាក់កោះទាំងនេះ* (រួមមានកោះត្រល់) *ឲ្យនៅក្រោមរដ្ឋបាល នៃកម្ពុជា*"(!)។

ចំណែកប្រទេសកម្ពុជា ក៏មិនដែលបានបោះបង់កោះត្រល់ ឲ្យទៅបារាំង ឬឲ្យទៅយៀកណាម ឡើយ តាំងពីសម័យ ព្រះបាទ អង្គ ឌួង រហូតដល់ សម័យព្រះបាទ សីហនុ, ព្រះបាទ សុរាម្រិត និងសម័យឧត្តមសេនីយ លន់ នល់។ របបខ្មែរក្រហម នៅឆ្នាំ១៩៧៥ និង១៩៧៦ បានកាន់កាប់ កោះត្រល់ និងប្រជុំកោះក្រចកសេះ និងវាយប្រហារ ទល់និងយួនហាណូយ ដែលជាការបញ្ជាក់ ចុងក្រោយ ថាកម្ពុជា មិនបោះបង់កោះត្រល់/កោះក្រចកសេះ ឲ្យទៅយួនឡើយ។ តែយួន បាន វាយប្រហារឈ្នះខ្មែរក្រហមវិញ ហើយកាន់កាប់កោះទាំងនោះ ពីពេលនោះមក។ នៅទីបំផុត យួនបានធ្វើជាកិច្ចព្រមព្រៀងមួយ ជាមួយហ៊ុន សែន ចុះថ្ងៃទី៧ កក្កដា ១៩៨២ ដែលកាត់យក កោះត្រល់ និងប្រជុំកោះក្រចកសេះ ដោយគ្មានចាំបាច់ លើកការសំអាងលើច្បាប់អ្វីទេ គឺលើ តែ"ស្ថានភាពជាក់ស្តែង" បន្ទាប់ពីគេវាយឈ្នះ ប៉ុល ពត នាឆ្នាំ១៩៧៦នោះ ប៉ុណ្ណោះ។

ការជាក់ស្តែង គឺ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនយោបាយនិងទឹកដី របស់យួន ឆ្នាំ១៩៧៩-១៩៨៩ ជាមួយខ្មែរ (ហេង សំរិន ជាពិសេស ហ៊ុន សែន) - ដែលសម្តេច សីហនុ បានប្រកែក មិនទទួលស្គាល់ដាច់ខាត - វាឈរលើគោលការណ៍ នៃពួកចក្រពត្តិនិយម នៃសតវត្សទី១៩ និង ពួក ហ៊ីត្លែរ (Hitler) (សតវត្សទី២០) ដែលគេថា គេជាអ្នកឈ្នះសង្គ្រាម គេអាចកាត់យកទឹកដី/ ប្លន់ទ្រព្យសម្បត្តិ របស់អ្នកចាញ់ បានតាមចិត្តគេ។ច្បាប់អន្តរជាតិ ជាអាទិ អនុសញ្ញា ក្រុងវីយែន (Vienne) ស្តីពីច្បាប់សន្ធិសញ្ញា (ចុះឆ្នាំ១៩៦៩) បានហាមដាច់ខាត មិនឲ្យមាន និងចាត់ទុកជា មោឃៈ រាល់សន្ធិសញ្ញា និងកិច្ចព្រមព្រៀង ទាក់ទិននិងបូរណភាពទឹកដី ឬឯកភាពជាតិ រវាង ភាគី ដែលមិនមានភាពស្មើគ្នា - ជាអាទិ រវាងអ្នកត្រួតត្រា និង អ្នកនៅក្រោមការត្រួតត្រានោះ។

ប៉ុន្តែ ក្នុងការអះអាងរបស់គាត់ ដោយភរភូត និងបំភ្លៃទាំងល្ងីតល្ងល់ ខាងលើនោះ គឺលោក ហ៊ុន សែន ខំរំលឹកបំពេញចិត្តយួនហាណូយ នាពេលនេះទៀត ដោយខំការពារ បន្ទាត់ព្រំដែន យៀកណាម-កម្ពុជា ដែលយួនបានគូសវាស ឲ្យគាត់ប្រើ តាំងពីឆ្នាំ១៩៨២មក។ យើងអាចមើល ឃើញផងដែរ ថា នាពេលដែលយួនខំប្រឹង បោះបង្គោលព្រំដែន ឲ្យចប់ នាឆ្នាំ២០១៨នេះ លោក ហ៊ុន សែន ក៏ប្រុងនឹងកែរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា២) ដើម្បីសម្រប តាមគំនូសនិងមាត្រាដ្ឋាន នៃផែនទី របស់យួននោះ។ នេះហើយ មនុស្ស"ខ្លាំង"នៃកម្ពុជា ! ។

គណៈកម្មាធិការព្រំដែនកម្ពុជាយើង សូមលើកម្តងទៀត នូវការទាមទារ ឲ្យលប់ចោលទាំង អស់ -ស្របតាមបទបញ្ញត្ត នៃកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា- នូវសន្ធិសញ្ញា និងកិច្ចព្រមព្រៀងនយោបាយនិងទឹកដី របស់យួន ឆ្នាំ១៩៧៩-១៩៨៩ - **ដើម្បីការរក្សាជានិរន្តរ៍ នូវ កិច្ចព្រមព្រៀងអន្តរជាតិប្រវត្តិសាស្រ្ត ទាំងអស់ និង លក្ខន្តិកៈអន្តរជាតិ នៃប្រទេសកម្ពុជា** - ព្រមទាំងការជំទាស់ដាច់ខាត និងការកែប្រែ មាត្រា២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

*ថ្ងៃទី២២ មិនា ២០១៨*

ជ. គណៈកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក

**ឌី ការ៉េត** - *ប្រធាន ស្តីទី*